តមកពីទំព័រទី ១ គ

គាត់នឹងធ្វើម្សៀសជូនហើយគេកប់សពទៅទៀត”ជាប្រធានបទនៃកម្មវិធីពន្លឺភ្លើងទៀនថ្ងៃម្សិល ។ កម្មវិធីនេះ លោកថាច់ សេដ្ឋា នាយកសហគមន៍ខ្មែរកម្ពុជាក្រោមជាវាគ្មិន ។ ក្នុងអារម្ភកថា (មុនឆ្លើយសំណួរតាមទូរស័ព្ទពីសវនិកជន) លោកថាច់ សេដ្ឋា បានថ្លែងថា “ខ្ញុំចង់ទុកជូនយោបល់ដល់ប្រជាពលរដ្ឋដែលតាមដានស្តាប់និងពិចារណាទាំងអស់គ្នាទៅតាមសម្តីរបស់មេដឹកនាំខ្មែរដែលនិយាយបែបនេះ ។ យើងពិភាក្សាទាំងអស់គ្នាមើលថាតើសម្តីនេះសក្តិសមជាថ្នាក់ដឹកនាំដែលទទួលខុសត្រូវចំពោះវាសនាប្រទេសជាតិរបស់យើងទាំងអស់គ្នាដែរឬទេ?”

លោកបន្តថា ពាក្យសម្តីដែលលោកនាយករដ្ឋមន្ត្រីលើកឡើងដូច្នេះ ខ្ញុំនឹកឃើញនិងស្រមៃដល់សម័យខ្មែរក្រហមដែលជាបទប្រល័យពូជសាសន៍ នៅពេលដែលកំពុងតែធ្វើបាបកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរ. ហើយមានគេជួយសង្គ្រោះបែរជាខ្មែរក្រហមស្រែកគំរាមអ្នកទៅជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរ ដែលឋិតនៅក្រោមការកាប់សម្លាប់នោះវិញ.តើយើងឈឺចាប់ដែរឬទេ? ហ្នឹងជាសំណួរមួយដែលយើងត្រូវគិតទាំងអស់គ្នា ។នោះគ្រាន់តែ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលបងប្អូនខ្មែររបស់យើងជនរួមឈាមរបស់យើងទទួលរងការកាប់សម្លាប់. ចុះទឹកដីកម្ពុជាក្រោមដែលត្រូវបាត់បង់ ប្រជារាស្ត្រខ្មែរដែលកើតឡើង ឃើញពន្លឺថ្ងៃពេលណា ឃើញតែការជិះជាន់សង្កត់ធ្វើបាបគ្រប់សព្វបែបយ៉ាងរាប់រយឆ្នាំមកហើយ តើទទួលការឈឺចាប់ប៉ុណ្ណាទៅ? ខ្ញុំជឿថាលោកនាយករដ្ឋមន្ត្រី គាត់ឋិតនៅក្នុងជនរងគ្រោះសម័យនោះដែរ. គាត់ឈឺចាប់ដែរ ។ តែបែរជាថ្ងៃនេះនិយាយបែបនេះទៅវិញ ។ តើនេះជាភាសាមួយទទួលខុសត្រូវដែរឬទេ? ហើយក្នុងឋានៈជាមេដឹកនាំ អាចលើកទឹកចិត្តដល់ប្រជាពលរដ្ឋសំរាប់ការតស៊ូដែរឬទេ? ទោះបីជាលោកមិនទៅចូលរួមក្នុងហ្នឹងក៏ដោយ រឿងចង់បានទឹកដីឬក៏មិនតស៊ូ មិនតវ៉ា ជារឿងរបស់ប្រជាពលរដ្ឋ ឬមួយទៀតថា បើការទាមទារកម្ពុជាក្រោមមកវិញ ឬមិនទាមទារនោះជារឿងរបស់នាយករដ្ឋមន្ត្រីខ្មែរ ជារឿងរបស់ស្ថាប័នយើង ព្រោះទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ ។បើថ្នាក់ដឹកនាំឬនាយករដ្ឋមន្ត្រីខ្លួនឯងមិនទាមទារឬមិនខ្វល់ខ្វាយនោះ ប្រវត្តិសាស្ត្រគេនឹងចារថែមតទៅទៀតក្នុងអាណត្តិយើងដឹកនាំនេះថាមិនបានខ្វល់ខ្វាយទេ។ មិនតែប៉ុណ្ណោះមេដឹកនាំហ៊ានវាយប្រហារខ្មែរ. ការពារយួន. ធ្វើឱ្យបងប្អូនខ្មែរកម្ពុជាក្រោមខកចិត្តថែមទៀតផង។ នេះប្រវត្តិសាស្ត្រគេកត់ត្រាទុករាល់សម្តីរបស់ថ្នាក់ដឹកនាំយើង។

ប្រជាពលរដ្ឋខ្មែរបានបញ្ចេញទស្សនៈតាមទូរស័ព្ទថា ខ្ញុំបានឮលោកមានប្រសាសន៍ពាក់ព័ន្ធជាមួយរដ្ឋាភិបាលខ្មែរយើង ដែលប្រើពាក្យថា “បើនរណាចង់បានទឹកដីកម្ពុជាក្រោម គាត់នឹងធ្វើក្តារម្ឈូសឱ្យ”សបញ្ជាក់ឱ្យឃើញថា នេះជាភាពខ្សោយរបស់ប្រមុខរដ្ឋាភិបាលដែលផ្តល់មតិឱ្យប្រជាពលរដ្ឋបាត់បង់ស្មារតី ។ដូចជាខ្ញុំក្នុងនាមជាយុវជន មិនអាចទទួលយកបានទេពីព្រោះអ្វីដែលយើងបាត់បង់ទៅនេះធ្វើឱ្យប្រជាពលរដ្ឋមិនសូវកក់ក្តៅទេ បើរដ្ឋាភិបាលមានប្រសាសន៍បែបនេះទៀត ធ្វើឱ្យប្រជាពលរដ្ឋកាន់តែរួញរា ។ហើយនេះក៏ជាយុទ្ធសាស្ត្រដ៏កំសោយមួយរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជន ។ ក្នុងនាមខ្ញុំជាប្រជាពលរដ្ឋម្នាក់ ខ្ញុំតែងតែការពារជាតិខ្លួន ចង់ការពារទឹកដីប្រទេសជាតិ ។ ប៉ុន្តែយើងបានទទួលការបន្ទាចពីថ្នាក់ដឹកនាំធ្វើឱ្យយុវជនដូចជាខ្ញុំមានការសោកស្តាយជាខ្លាំង ។ ដូចយើងឃើញស្រាប់ហើយ នៅតាមទីផ្សារក៏ដោយ តាមភូមិ ឃុំ សង្កាត់ តែងតែមានជនអន្តោប្រវេសន៍យួនខុសច្បាប់ ចូលមករស់នៅគគ្រឹកគគ្រេង ធ្វើឱ្យប្រជាពលរដ្ឋខ្មែរយើងមិនអាចនៅទីប្រជុំជនបានទេ ដោយសារហេតុផលត្រង់ថាជនអន្តោប្រវេសន៍យួនខុសច្បាប់ចូលមកបោះឆ្នោតអោយគណបក្សប្រជាជន១ជួយប្រជាជនយួនច្រើនជាងប្រជាពលរដ្ឋខ្មែរហើយធ្វើអោយប្រជាពលរដ្ឋខ្មែរកាន់តែចាកចេញពីទីក្រុងអស់។ សូមលោកថាច់សេដ្ឋាមេត្តាជួយប្រាប់ប្រជាពលរដ្ឋផង ។ ខ្ញុំមានការសោកស្តាយដែលប្រមុខរដ្ឋាភិបាលយើងបានបន្ទោសទៅលើប្រជាពលរដ្ឋថាប្រជាពលរដ្ឋគ្មានធនធានមនុស្សដើម្បីទទួលបានប្រាក់ខែច្រើន ។ ប្រមុខរដ្ឋាភិបាលមិនត្រូវបន្ទោសប្រជាពលរដ្ឋទេ ។ ត្រូវតែបង្ហាត់បង្រៀនប្រជាពលរដ្ឋអោយចេះដឹងដើម្បីទទួលបានប្រាក់ខែច្រើនដូចប្រជាពលរដ្ឋគេ ។ ប៉ុន្តែរដ្ឋាភិបាលខ្មែរយើងខ្វះការទទួលខុសត្រូវ ហើយមិនអាណិតអាសូរដល់ប្រជាពលរដ្ឋក្រីក្រនោះទេ ។ ក្នុងនាមខ្ញុំជាប្រជាយុវជននិងជាប្រជាពលរដ្ឋ ខ្ញុំត្រូវការមានការងារធ្វើ មានការព្យាបាលដោយមិនបង់ប្រាក់ និងមានជីវភាពរស់នៅសមរម្យ ។ ខ្ញុំត្រូវការអ្នកដែលគិតគូរដល់ប្រទេសជាតិ ពិសេសអ្នកដែលគិតដល់សេដ្ឋកិច្ចជាតិនិងរក្សាទឹកដីឱ្យបានគង់វង្ស។

ប្រជាពលរដ្ឋម្នាក់ទៀតរៀបរាប់: ខ្ញុំជាប្រជាពលរដ្ឋខ្មែរម្នាក់ស្រឡាញ់ទឹកដីខ្មែរ ស្រឡាញ់ប្រជារាស្ត្រខ្មែរ។ តែខ្ញុំបានឮសម្តីមេដឹកនាំខ្មែរយើងបែបនេះ ខ្ញុំមានការខកចិត្តយ៉ាងខ្លាំង។ ខ្ញុំចង់សួរទៅលោកពីរសំណួរ: ១-សួរថាតើមេដឹកនាំខ្មែរសព្វថ្ងៃគាត់ចាត់ទុកកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរដែរឬទេ? ២-តើរាល់ពេលដែលអាជ្ញាធរយួនធ្វើទុក្ខបុកម្នេញដល់ប្រជាពលរដ្ឋកម្ពុជាក្រោម ហេតុអ្វីបានជាមេដឹកនាំយើងមិនអើពើ មិនរកវិធីដោះស្រាយដើម្បីជួយដល់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម?

លោកសេដ្ឋាឆ្លើយថា ខ្ញុំមិនខុសពីអស់លោកដែរ មានការរន្ធត់ចិត្តយ៉ាងខ្លាំងនិងសោកស្តាយចំពោះមេដឹកនាំខ្មែរម្នាក់ ដែលប្រើភាសាមួយធ្វើឱ្យប្រជាពលរដ្ឋខ្មែរយើងខកចិត្ត។ ភាសានេះមិនសក្តិសមជាមេដឹកនាំទេ ។ ទឹកដីមួយម៉ែត្រក្រឡា មួយចម្អាម ឬមួយម៉ែត្រ អាចកាប់សម្លាប់គ្នា... បើបាត់បង់ មានការសោកស្តាយណាស់ ។ តែចំពោះទឹកដីរបស់យើងបាត់បង់រាប់ម៉ឺនម៉ែត្រ រាប់សែនម៉ែត្រក្រឡានិងប្រជារាស្ត្រខ្មែររាប់លានត្រូវទទួលរងគ្រោះ. ប៉ុន្តែបែរជាមិនបានការលើកទឹកចិត្ត ការយកអាសា ការតាំពារតាមផ្លូវច្បាប់. បែរជាមានតែការបំបាក់ស្មារតីនៃការតស៊ូប្រជារាស្ត្រខ្មែរទៅវិញ។

ដូចខ្ញុំបានលើកខាងដើមថា យើងធ្លាប់ឈឺចាប់ក្នុងរបបខ្មែរក្រហមដែលធ្វើបាបយើង កាប់សម្លាប់យើង ហើយបើមានគេជួយយកអាសា បែរជាថាបើនរណាទៅជួយរំដោះ ធ្វើក្តារម្ឈូស. តើយើងសប្បាយចិត្តទេ ដែលយើងកំពុងរងគ្រោះក្នុង នោះក៏មាននាយករដ្ឋមន្ត្រីម្នាក់ដែរ ។ យើងជាប្រជាពលរដ្ឋខ្មែរទាំងអស់គ្នាពិចារណាមើលចុះ។

ចំពោះថា តើលោកចាត់ទុកជាទឹកដីខ្មែរឬទេ? ខ្ញុំគិតថា បើសិនជាមេដឹកនាំមានសម្បជញ្ញៈ មានការទទួលខុសត្រូវ ហើយមេដឹកនាំដែលស្នេហាជាតិ មេដឹកនាំមានឧត្តមគតិជាតិ ហើយមិនឋិតនៅក្នុងអាយ៉ងបរទេសដែលមិនបំរើបរទេស. បម្រើខ្មែរ. ការពារប្រជាពលរដ្ឋខ្មែរ. គាត់ចាត់ទុកទឹកដីកម្ពុជាក្រោម ជាទឹកដីរបស់ខ្មែរហើយ ។ ទឹកដីកម្ពុជាក្រោមគ្រាន់តែបាត់បង់ដោយសារបច្ចុប្បន្នយួនជាអ្នកគ្រប់គ្រង ពិសេសគេនឹងយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋខ្មែរជាង១២លាននាក់ដែលកំពុងរស់នៅយ៉ាងវេទនា ខំថែរក្សាទំនៀមទម្លាប់ប្រពៃណី ភាសាសាស្ត្ររហូតមកដល់បច្ចុប្បន្ននេះ. គេត្រូវតែលើកទឹកចិត្តបន្ថែមទៀត ។ មិនមែនលើកទឹកចិត្តថា ពួកនេះសុទ្ធតែបំផ្លាញជាតិ ។ ខ្លួនឯងពាក់មេដៃមិនចេះខ្មាសខ្លួន ជាអ្នកបំផ្លាញជាតិគ្រប់សព្វបែបយ៉ាង ចូលរួមប្រព្រឹត្តអំពើពុករលួយ ធ្វើបាបរាស្ត្រខ្មែរគ្មានឯងអត់ចេះខ្មាសខ្លួនឯង ។គេខំប្រឹងបំរើជាតិដើម្បីរក្សាប្រពៃណីខ្មែរទំនៀមទម្លាប់ខ្មែរដូចគ្នា បែរជាខំជាន់ពន្លិច បំបាក់ស្មារតីទៅវិញ ។ខ្ញុំយល់ថា ប្រជារាស្ត្រខ្មែរលោកយល់ណាស់ដែលខំប្រឹងតស៊ូរហូតដល់ប៉ុណ្ណឹង។ លោកមិនខ្វល់នឹងអ្វីដែលមេដឹកនាំខ្មែរលើកឡើងនោះទេ។

មួយវិញទៀតសួរថា ពេលដែលយួនធ្វើបាបប្រជាពលរដ្ឋខ្មែរ ហេតុអីបានជារដ្ឋាភិបាលខ្មែរមិនជួយធ្វើអន្តរាគមន៍? -នេះជាការពិតហើយដែលផ្ទុយពីរដ្ឋាភិបាលយួន ។ នៅពេលណាខ្មែរធ្វើបាបប្រជាពលរដ្ឋគេណាមួយ គេតែងតែចុះជួយធ្វើអន្តរាគមន៍ជានិច្ច។ ឧទាហរណ៍ ដូចជាកាលជំនាន់លោកជា សុផារ៉ា ជាអភិបាលក្រុងភ្នំពេញ ពេលដែលយួនមានបញ្ហាគ្នាគេនៅចាក់អង្រែ គេធ្វើអន្តរាគមន៍ភ្លាម១ គេការពារគ្នាគេភ្លាម ។ឯប្រមុខរដ្ឋាភិបាលខ្មែរទោះបីជាមានច្បាប់ចែងនៅក្នុងរដ្ឋធម្មនុញ្ញក៏ដោយ មានច្បាប់ការពារខ្មែរនៅបរទេសគ្រប់ទិសទីក៏ដោយ ក៏គាត់មិនបានយកចិត្តទុកដាក់ដែរ ។ យើងមើលឃើញថា គាត់បានអំណាចដោយសារយួន ហេតុនេះគាត់មិនអាចធ្វើអ្វីឱ្យប៉ះពាល់ដល់យួនបានទេ ។គាត់ត្រូវតែខ្លាចចៅហ្វាយនាយរបស់គាត់ ។ ខ្ញុំសូមជំរាបជូនបងប្អូនដោយត្រង់១ ។បើសិនជាគាត់ឋិតក្នុងនាមជាជនរួមជាតិខ្មែរ ជាមេដឹកនាំខ្មែរពិតប្រាកដ គាត់ត្រូវតែការពារ ព្រោះរដ្ឋធម្មនុញ្ញមានចែងហើយថា “រដ្ឋាភិបាលខ្មែរមានកាតព្វកិច្ចតាំពារដល់ប្រជាពលរដ្ឋខ្មែរនៅបរទេស ទោះបីនៅទីណាក៏ដោយ” ។ផ្ទុយទៅវិញរដ្ឋាភិបាលយកចិត្តទុកដាក់ទៅលើប្រជាពលរដ្ឋនៅប្រទេសថៃ នៅអាមេរិកឯណាឯណីទៅវិញ។ ឯខ្មែរក្រោមគាត់មិនហ៊ាននិយាយអីទាល់តែសោះ.ហើយធ្វើទុក្ខបុកម្នេញដល់ខ្មែរក្រោមថែមទៀតផង មានទាំងចាប់ព្រះសង្ឃផ្សឹក ហើយបញ្ជូនទៅអោយយួនដាក់ទោសជាដើម។

ចំណែករឿងក្រុមហ៊ុនវិនិយោគឬសម្បទានអីនោះនៅពេលដែលគណបក្សសម រង្ស៊ី ឈ្នះឆ្នោត គណបក្សមើលឃើញថាមិនបានបំរើដល់ផលប្រយោជន៍របស់ជាតិ គណបក្សនឹងសើរើបញ្ហាទាំងនេះឡើងវិញថា តើមួយណាគួរទុក មួយណាត្រូវដកហូត ។

សំណួរៈ តើអន្តរជាតិអាចជួយដោះស្រាយបញ្ហាទឹកដីខ្មែរកម្ពុជាក្រោមបានទេ? ខ្ញុំសូមអំពាវនាវដល់ខ្មែរកុំឱ្យបាត់ស្មារតីឱ្យសោះ ត្រូវតែមានគំនិតទាមទារមកវិញឱ្យបាន។

ថាច់ សេដ្ឋាៈ ខ្ញុំសូមអរគុណចំពោះបងប្អូនខ្មែរអ្នកស្នេហាជាតិមានចិត្តចង់ជួយខ្មែរជាងមេដឹកនាំសព្វថ្ងៃនេះ ។ យើងហ៊ានបូជាជីវិតអាណិតស្រឡាញ់ទឹកដីរបស់ជនជាតិខ្លួនឯង ដែលវាផ្ទុយទាំងស្រុងពីមេដឹកនាំរបស់យើងដែលបានលើកឡើង ដោយមើលងាយវិញ្ញាណក្ខន្ធអ្នកតស៊ូដើម្បីទឹកដីខ្មែររបស់យើង ។ យើងមិនថាកម្ពុជាក្រោម កម្ពុជាកណ្តាល កម្ពុជាលើអីទេ។ ភាសាទាំងអស់ហ្នឹង សុទ្ធតែជាភាសាបែងចែកធ្វើឱ្យជាតិរបស់យើងបែកបាក់ ។ យួនវាមានយុទ្ធសាស្ត្រមិនអោយខ្មែរកណ្តាលខ្មែរក្រោមខ្មែរលើរួបរួមគ្នាកើត ព្រោះកាលណារួបរួមគ្នាខ្មែរយើងមានច្រើនមានកម្លាំងខ្លាំង ។ គេធ្វើយុទ្ធសាស្ត្រគ្រប់បែបយ៉ាង ឱ្យខ្មែរកណ្តាលស្អប់ខ្មែរក្រោម១ឡើងមកគេថាជាយួន ។ ខ្មែរក្រោមមកធ្វើអត្តសញ្ញាណប័ណ្ណគេមិនធ្វើឱ្យ ។ក្រៅពីនោះទៀតរដ្ឋាភិបាលយើងបានសម្តែងការកំសាក មិនលើកទឹកចិត្តឱ្យប្រជាពលរដ្ឋខ្មែរមានស្មារតី ការពារជាតិឡើយ សូម្បីតែបរទេសក៏គេស្រឡាញ់និងស្តាយស្រណោះចំពោះប្រជាជាតិយើងស្ទើរគ្រប់គ្នាដែរ ។

ជាចុងបញ្ចប់ សូម្បីតែបងប្អូនខ្មែរយើងបានសម្តែងនូវការទាមទារទឹកដីកម្ពុជាក្រោមមកវិញ. តែបានឬមិនបាន គឺឋិតនៅលើរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ព្រះមហាក្សត្រ ។ បើសិនជាស្ថាប័នជាតិយើងចង់បាន យើងត្រូវតែសម្រេចជោគវាសនារបស់ប្រទេសជាតិរបស់យើង ព្រោះទឹកដីកម្ពុជាក្រោមជាទឹកដីរបស់យើងតាំងពីដើមរហូតមក.ឥឡូវនេះក៏មិនទាន់ថាទៅជាយួនទាំងស្រុងដែរ។ ទោះបីជាយើងចាត់ទុកថាជាទឹកដីរបស់យួន តែខ្មែរក្រោមភាគច្រើននៅតែចាត់ទុកថាជាទឹកដីរបស់ខ្មែរយើងជាដដែល ។ បើគិតពីអាជ្ញាយុកាលក៏វាមិនហួសដែរ។ បើគិតពីការតស៊ូ ខ្មែរយើងនៅតែតស៊ូទាមទារទឹកដីកម្ពុជាក្រោមតាំងពីឆ្នាំ១៩៧៦មកម្លេះ. ហើយថ្មី១នេះនៅមានការទាមទារជាបន្តបន្ទាប់។ ទាំងអស់នេះគឺបានន័យថា រឿងទាមទារមិនទាមទារនោះជាភារកិច្ចរបស់មេដឹកនាំខ្មែរ របស់នាយករដ្ឋមន្ត្រីខ្មែរ ដែលគាត់ទទួលខុសត្រូវវាសនាជាតិមិនមែនជារឿងរបស់ប្រជាពលរដ្ឋតូចតាចទេ ព្រោះកម្ពុជាក្រោមជាកម្មសិទ្ធិជាអតីតទឹកដីរបស់ខ្មែរយើង។

ប្រជាពលរដ្ឋខ្មែរយើងនៅកម្ពុជាក្រោម គាត់ទាមទារទឹកដីរបស់គាត់ដែលត្រូវបាត់បង់ដោយសារយួនវាយកដី ហើយធ្វើបាបគ្រប់បែបសព្វយ៉ាង ។ ថ្មី១នេះគេវាយគេសម្លាប់ដុតផ្ទះសម្បែង គេធ្វើបាបព្រះសង្ឃខ្មែរក្រោម គេចាប់ដាក់គុកដាក់គ្រប់សព្វបែបយ៉ាង ។ យើងមិនដែលឮនាយករដ្ឋមន្ត្រីខ្មែរហើបមាត់មួយម៉ាត់ដើម្បីជួយធ្វើ អន្តរាគមន៍ទេ។ មានតែបន្ទោសថែម ។

ឯរឿងអន្តរជាតិជួយយើងបានទេនោះ ។ ត្រង់នេះទាល់តែយើងជួយខ្លួនយើងសិន ទើបអន្តរជាតិគេជួយយើង ដូចជាទៅកូសូវ៉ូជាដើមដែលដណ្តើមបានឯករាជ្យដោយសារតែគេធ្វើសកម្មភាពតវ៉ាខ្លាំង ទើបអន្តរជាតិគាំទ្រ ។ បើយើងនៅស្ងៀម១ មិនហ៊ាននិយាយ ទៅសម្ងំទាំងអស់គ្នា និងបំបាក់ស្មារតីទៀតនោះ វាក៏មិនអាចទៅរួចដែរ។

ឯបញ្ហាអាណត្តិគឺមាន ។ ក្នុងប្រទេសកម្ពុជាយើង មានការកំណត់អាណត្តិ ប្រជាពលរដ្ឋខ្មែរយើងអាចទម្លាក់នាយករដ្ឋមន្ត្រីបានតាមរយៈការបោះឆ្នោត ។ តែឥឡូវនេះ នាយករដ្ឋមន្ត្រីអាងអំណាច ។ នៅពេលដែលយើងឃើញនាយករដ្ឋមន្ត្រីនិយាយខុសបែបនេះ តើយើងហ៊ានទៅហៅនាយករដ្ឋមន្ត្រីមកសួរនាំទេ ប្រាកដជាមិនអាចទេ ក្រៅពីតំណាងរាស្ត្រគណបក្សសម រង្ស៊ីនៅក្នុងរដ្ឋសភា ។ ឯតំណាងរាស្ត្រផ្សេងពីគណបក្សសម រង្ស៊ីគេការពារតែថ្នាក់ដឹកនាំប៉ុណ្ណោះ ។ បើយើងហៅគេ. គេយករថក្រោះពីរបីគ្រឿងមកការពារ យើងមិនរត់ជាន់គ្នាហើយ! ដូច្នេះអំណាចរបស់គាត់វាខ្លាំងជាងច្បាប់ទៅទៀត ។ នៅប្រទេសគេបើប្រើភាសាខុសបែបនេះ ប្រជាពលរដ្ឋបណ្តេញចេញពីតំណែងបានព្រោះគេគោរពច្បាប់ ។តែនៅស្រុកខ្មែរយើង ទោះគេចង់ជាន់ក្បាលនរណា គេបំផ្លាញជាតិប៉ុណ្ណា ក៏គ្មាននរណាហ៊ានទម្លាក់ដែរ ព្រោះតែអំណាចផ្តាច់ការរបស់ក្រុមគេ។ ក្នុងប្រទេសយើងមានច្បាប់គ្រប់គ្រាន់ដើម្បីអនុវត្តហើយ តែអ្នកដែលអនុវត្តច្បាប់ គេមិនគោរពច្បាប់ ។ លុះត្រាតែគណបក្សប្រជាធិបតេយ្យឡើងកាន់អំណាច គោរពច្បាប់ច្បាស់លាស់ ទើបយើងអាចកែប្រែប្រទេសយើងឡើងវិញឱ្យបានត្រឹមត្រូវ។

ទឹកដីខ្មែរមិនមែនត្រឹមតែខេត្តស្វាយរៀង ក្រចេះ កំពង់ចាម តាកែវប៉ុណ្ណឹងនោះទេ តាមពិតទៅដល់មាត់សមុទ្រខាងកើតឯណោះ ។ តាំងពីសម័យស្តេចជ័យជេដ្ឋាទី២ដែលយើងតែងតែថាព្រះអង្គយកប្រពន្ធយួន មហេសីយួនរហូតដល់សព្វថ្ងៃនេះ ក៏មិនដែលប្រមុខរដ្ឋាភិបាលណាមួយ ឬស្តេចណាមួយគេធ្វើការកំណត់ព្រំដែនឬចុះហត្ថលេខា ឬសន្ធិសញ្ញាណាមួយទៅលើទឹកដីខ្មែរក្រោមទាំងអស់នោះទៅឱ្យយួនដែរ ។ វាគ្រាន់តែជារដ្ឋបាលអាណានិគមសម័យបារាំងឆ្នាំ១៩៤៥តែប៉ុណ្ណោះ សម្រាប់គ្រប់គ្រងរដ្ឋបាលទេ ។ តែមកដល់សម័យបច្ចុប្បន្នយើងនេះ បង្ហាញនូវភាពក្លាហានក្នុងការកំណត់ព្រំដែន។ ខ្ញុំកាលនៅជាសមាជិកព្រឹទ្ធសភាប្រឆាំងដាច់ខាត មិនអាចទទួលយកបានទេ ។ ខ្ញុំចាត់ទុកទឹកដីខ្មែរកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរទោះបីខ្ញុំស្លាប់ប៉ុន្មានជាតិក៏ដោយ ។ កាលនោះគណបក្សសមរង្ស៊ីក៏ប្រឆាំងដាច់ខាតចំពោះបញ្ហាកំណត់ព្រំដែននោះដែរ។ ខ្ញុំក៏បានចាកចេញពីអង្គប្រជុំ មិនយល់ព្រមជាដាច់ខាត ។ក្នុងពេលនោះ យើងពិបាកនិយាយណាស់ សមាជិកខ្លះលើកដៃទាំងធ្មេចភ្នែកដើម្បីសំរបតាមច្បាប់បំពេញបន្ថែមនេះ។

បងប្អូនជនរួមជាតិខ្មែរយើងបានយល់ហើយពីបញ្ហាប្រទេសជាតិយើង ។ អ្វីដែលយើងបានឮសម្តីលោកនាយករដ្ឋមន្ត្រីនិយាយបែបនេះ ធ្វើអោយខ្មែរយើងមានការឈឺចាប់ខ្លាំងណាស់. វាធ្ងន់ធ្ងរពេកហើយ ។ដូច្នេះសូមបងប្អូនពិចារណាមើលទៅ កុំគិតថាគណបក្សណាជាគណបក្សណាឱ្យសោះ ក្នុងនាមខ្លួនយើងជាខ្មែរ ។ តើយើងគួរជ្រើសរើសមេដឹកនាំដែលគិតពីប្រទេសជាតិ គិតពីប្រជារាស្ត្រខ្មែរ ឬមួយចង់យកមេដឹកនាំដែលមិនគិតពីខ្មែរ ទុកឱកាសឱ្យមេដឹកនាំធ្វើបាបខ្មែរគ្រប់ពេលវេលាបែបនេះទៅវិញ?

អំពីបងម្នាក់ដែលចង់បានដាក់ផែនទីខ្មែរកម្ពុជាក្រោមនៅតាមសាលារៀននោះ វាអាស្រ័យទៅលើក្រសួងអប់រំត្រូវបញ្ចូលទៅក្នុងកម្មវិធីសិក្សាទាក់ទងនឹងរឿងកម្ពុជាក្រោមនិងទឹកដីដែលត្រូវបាត់បង់ជាមួយថៃ ។ ក្នុងកម្មវិធីសិក្សានេះសោត ពេលនេះមិនបានបង្ហាញឱ្យបានច្បាស់លាស់ពីទឹកដីដែលបាត់បង់នោះទេ។ ដូច្នេះមានតែកម្មវិធីនៅក្នុងការអប់រំនេះមួយទេ ដែលធ្វើអោយសិស្សបានយល់ច្បាស់អំពីប្រវត្តិនៃទឹកដីរបស់ខ្លួន ប្រជាពលរដ្ឋរបស់ខ្លួនមាននៅទីណាខ្លះនោះ ។ ឯបញ្ហាដោះស្រាយដោយមិនមានបង្ហូរឈាមទៅលើទឹកដីដែលបាត់បង់នោះ យើងមានតែប្តឹងទៅតុលាការអន្តរជាតិទេ ។ រាល់ការទាមទារតាមផ្លូវច្បាប់នៅតែមានសុពលភាពនៅឡើយ ដោយគ្រាន់តែរដ្ឋាភិបាលយើងប្តឹងទៅតុលាការយុត្តិធម៌ជាការស្រេច ៕

ហ្ស៊ូលាន ZHULIAN
Aloe Vera
ភេសជ្ជៈ វេគី-វេរ៉ា
ប្រឆាំងកន្ទួលក្រហម ទឹកឃ្មុំ
ពិសេសសំរាប់ការឈឺរលាកក្រពះ
ពោះវៀន តំរងនោម ទល់លាមក
សំរួលប្រព័ន្ធរំលាយអាហារ
អាការៈក្តៅក្នុង និងពង្រឹងប្រព័ន្ធការពារ
មានលក់នៅផ្សារធំថ្មីផែនសលធល់មុខគាំបូឌីយ៉ា 011/012/015 75 99 91
VEGI VERA
Honey-Bee Pollen